**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងនិងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការតែងតាំងនិងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម ដើម្បីធានាការត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិដែលស្ថិតក្រោមសមត្ថកិច្ចរបស់ **ប.ស.ស.** ដែលមានកំណត់ក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការធ្វើអធិការកិច្ចសន្តិសុខសង្គមគ្រប់សហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធទាំងអស់ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ការតែងតាំងអធិការសន្តិសុខសង្គម

### ផ្នែកទី១

### គុណវុឌ្ឍិ

**មាត្រា៣ .-**

បេក្ខជនអធិការសន្តិសុខសង្គម ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

- មានអតីតភាពការងារក្នុងក្របខ័ណ្ឌមុខងារសាធារណៈយ៉ាងតិច១០(ដប់)ឆ្នាំ ឬបានបម្រើការងារនៅ **ប.ស.ស.** យ៉ាងតិច៥(ប្រាំ)ឆ្នាំ
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើង
- មានបទពិសោធផ្នែកសន្តិសុខសង្គមឬវិស័យការងារត្រូវទុកជាអាទិភាព
- ចេះប្រើប្រាស់កុំព្យូទ័រច្បាស់លាស់
- មិនធ្លាប់ទទួលរងការពិន័យឬវិធានការរដ្ឋបាលរបស់អង្គភាព ឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹមឬបទឧក្រិដ្ឋណាមួយ។

### ផ្នែកទី២

### ការប្រឡងជ្រើសរើសនិងការបណ្តុះបណ្តាល

**មាត្រា៤ .-**

ចំនួនអធិការសន្តិសុខសង្គមដែលត្រូវជ្រើសរើស ត្រូវសមាមាត្រទៅនឹងចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីក្នុង **ប.ស.ស.** និងតាមទំហំការងាររបស់អធិការកិច្ចសន្តិសុខសង្គម បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលមានគុណវុឌ្ឍិដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យនេះ ត្រូវបានជ្រើសរើសជាអធិការសន្តិសុខសង្គម ដោយឆ្លងកាត់ការប្រឡងជ្រើសរើសនិងការបណ្តុះបណ្តាលជំនាញអធិការកិច្ចសន្តិសុខសង្គម ជាប់ជាស្ថាពរ។

**មាត្រា៥ .-**

ការប្រឡងជ្រើសរើសអធិការសន្តិសុខសង្គម ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការប្រឡង ដែលមានសមាសភាពដូចខាងក្រោម៖

- អគ្គនាយក **ប.ស.ស.** ប្រធាន
- អគ្គនាយករង **ប.ស.ស.** អនុប្រធាន
- ប្រធាននាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម សមាជិក
- ប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស សមាជិក
- ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **ប.ស.ស.** សមាជិក។

ការបង្កើតគណៈកម្មការ បែបបទ និងនីតិវិធីនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

កម្មវិធីបណ្តុះបណ្តាលជំនាញអធិការកិច្ចសន្តិសុខសង្គម ត្រូវរៀបចំដោយគណៈកម្មការគ្រប់គ្រងវគ្គបណ្តុះបណ្តាល ដែលបង្កើតដោយសេចក្តីសម្រេចរបស់អគ្គនាយក **ប.ស.ស.**។

គណៈកម្មការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលមានសមាសភាពដូចមាត្រា៥នៃអនុក្រឹត្យនេះ។

ការបង្កើតគណៈកម្មការ បែបបទនិងនីតិវិធីនៃការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាល ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ផ្នែកទី៣
## បែបបទនៃការតែងតាំង

**មាត្រា៧ .-**

សមាសភាពជាក់ស្តែងរបស់អធិការសន្តិសុខសង្គម ត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៨ .-**

ប្រធាននាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម ត្រូវទទួលបាននីតិសម្បទាជាអធិការសន្តិសុខសង្គមដោយស្វ័យប្រវត្តិ និងមានសិទ្ធិអនុវត្តភារកិច្ចជាអធិការសន្តិសុខសង្គម។

**មាត្រា៩ .-**

អធិការសន្តិសុខសង្គមមានឋានៈស្មើគ្នាជាមួយនឹងមុខតំណែងគ្រប់គ្រងអង្គភាពក្នុង **ប.ស.ស.**។

**មាត្រា១០ .-**

ប្រាក់បំណាច់មុខងារនៃអធិការសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់អធិការសន្តិសុខសង្គម

**មាត្រា១១ .-**

អធិការសន្តិសុខសង្គម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យនិងតាមដានការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមដែលស្ថិតក្រោមសមត្ថកិច្ចរបស់ **ប.ស.ស.**

- ចុះធ្វើអធិការកិច្ចសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធតាមផែនការកំណត់ ឬតាមសំណើរបស់អង្គភាពឬបុគ្គលពាក់ព័ន្ធដោយមិនចាំបាច់ជូនដំណឹងជាមុន ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ស្នើសុំការពិន័យអន្តរការណ៍ឬស្នើសុំដាក់ពាក្យបណ្ដឹងទៅតុលាការរាល់បទល្មើស ដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម
- ផ្ទៀងផ្ទាត់និងផ្ដល់អនុសាសន៍អំពីភាពខ្វះចន្លោះក្នុងការអនុវត្តកាតព្វកិច្ចរបស់សហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធ
- សាកសួរព័ត៌មានពីនិយោជក សហជីព ឬប្រតិភូបុគ្គលិក ឬកម្មករនិយោជិត ឬបុគ្គលដែលពាក់ព័ន្ធ ទាក់ទងនឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានា
- ស្នើសុំកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងករណីដែលសហគ្រាស គ្រឹះស្ថានមិនព្រមសហការ ឬមិនអនុញ្ញាតឱ្យចូលបំពេញភារកិច្ច
- អង្កេតឧប្បទ្ទវហេតុឬគ្រោះថ្នាក់នានាតាមការចាំបាច់ ដើម្បីបញ្ជាក់ភាពត្រឹមត្រូវពាក់ព័ន្ធនឹងហានិភ័យការងារដែលមានលក្ខណៈស្មុគស្មាញ ឬស្នើសុំអគ្គនាយក **ប.ស.ស.** ដើម្បីកែតម្រូវសេចក្ដីសម្រេចរបស់នាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម
- ស្នើទៅអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការបន្ទាន់ ដើម្បីទប់ស្កាត់មិនឱ្យនិយោជកចាកចេញពីព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលមិនបានបង់ភាគទានសន្តិសុខសង្គមមក **ប.ស.ស.** ដែលអាចនាំឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់កម្មករនិយោជិតរបស់ខ្លួន
- ដាក់កំហិតឬណែនាំដល់និយោជកក្នុងសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធ ឬដល់កម្មករនិយោជិតអំពីការមិនអនុវត្តបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤
## ក្រមសីលធម៌របស់អធិការសន្តិសុខសង្គម

**មាត្រា១២ .-**

ក្នុងការអនុវត្តការងារ អធិការសន្តិសុខសង្គមត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈជាអាទិ៍មានភាពម្ចាស់ការ ភាពមិនលម្អៀង សុចរិតភាព អាកប្បកិរិយាថ្លៃថ្នូរ ការប្រាស្រ័យទាក់ទងល្អ ការរក្សាអាថ៌កំបាំងវិជ្ជាជីវៈ និងមានការប្រកាន់ខ្ជាប់វិជ្ជាជីវៈ។

## ជំពូកទី៥
## បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចសន្តិសុខសង្គម

**មាត្រា១៣ .-**

ក្នុងពេលបំពេញបេសកកម្ម អធិការសន្តិសុខសង្គមត្រូវស្លៀកពាក់ឯកសណ្ឋាននិងសញ្ញាសម្គាល់ព្រមទាំងមានលិខិតអនុញ្ញាតឱ្យបំពេញបេសកកម្មចេញដោយអគ្គនាយក **ប.ស.ស.**។

ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់អធិការសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**មាត្រា១៤ ._**

ក្នុងការធ្វើអធិការកិច្ចសន្តិសុខសង្គម **ប.ស.ស.**ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងតិច៣(បី)ថ្ងៃនៃថ្ងៃធ្វើការ មុនការចុះធ្វើអធិការកិច្ច ចំពោះសហគ្រាស គ្រឹះស្ថាន មិនទាន់ចុះបញ្ជីនៅ **ប.ស.ស.**។

អធិការសន្តិសុខសង្គមអាចចុះធ្វើអធិការកិច្ចដោយមិនបាច់ជូនដំណឹងជាមុន ក្នុងករណីដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានៈ

- មិនអនុវត្តកាតព្វកិច្ចចុះបញ្ជីសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតតាមការដាក់កំហិត
- មិនអនុវត្តកាតព្វកិច្ចនៃការបង់ភាគទានតាមកាលកំណត់
- មិនអនុវត្តកាតព្វកិច្ចរាយការណ៍អំពីចំនួនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ
- ប្រកាសប្រាក់ឈ្នួលជាប់ភាគទានមិនត្រឹមត្រូវ
- ដកយកភាគទានមិនអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់
- តាមសំណើរបស់សមាជិក **ប.ស.ស.** ឬអង្គភាពពាក់ព័ន្ធ។

ទម្រង់លិខិតជូនដំណឹងចុះធ្វើអធិការកិច្ច ត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

**មាត្រា១៥ ._**

គ្រប់ការចុះធ្វើអធិការកិច្ច អធិការសន្តិសុខសង្គមត្រូវធ្វើកំណត់ហេតុនិងអាចភ្ជាប់លិខិតដាក់កំហិតតាមករណីនីមួយៗ ដោយទុករយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដើម្បីឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានអនុវត្តកាតព្វកិច្ចតាមច្បាប់ជាធរមាន។ ចំពោះការចុះធ្វើអធិការកិច្ចចុះបញ្ជិកា ផុតរយៈពេលខាងលើ អធិការសន្តិសុខសង្គមត្រូវធ្វើអធិការកិច្ចម្តងទៀត និងចេញលិខិតពិន័យអន្តរការណ៍ស្របតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម។

កំណត់ហេតុនិងលិខិតដាក់កំហិតរបស់អធិការសន្តិសុខសង្គម ត្រូវប្រគល់ឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានចំនួន១(មួយ)ច្បាប់ដើម្បីអនុវត្ត។

ទម្រង់នៃកំណត់ហេតុ លិខិតដាក់កំហិត និងលិខិតពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

អគ្គនាយក **ប.ស.ស.** ត្រូវចេញគោលការណ៍ណែនាំលម្អិតស្តីពីបែបបទ នីតិវិធី និងរបៀបរបបការងារអធិការកិច្ចសន្តិសុខសង្គម។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ ._**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលពាក់ព័ន្ធនឹងការតែងតាំងអធិការសន្តិសុខសង្គម ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣ រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល**:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ